# ការចាប់ផ្ដើមការងារថ្មីរបស់សមាគមន៍

ការរីករាលដាលនៃមេរោគកូវីដនៅតែបន្ត។ខាងសមាគមន៍បានរួមគ្នាផ្ដួចផ្ដើមនូវការងារថ្មីដើម្បីការពារការរីករាលដាលនៃមេរោគត្រូវប្រឹងប្រែងដើម្បីឆ្លងកាត់ពេលវេលាដ៏លំបាកនេះ។

### NEW ការគាំទ្រការបង្កើតគេហទំព័រ

មានក្រុមហ៊ុនជាច្រើនដែលតែងតែចង់បានគេហទំព័រក្រុមហ៊ុនផ្ទាល់ខ្លួនតែពិបាកនៅក្នុងការបង្កើតវា។ពីខាងសមាគមន៍យើងខ្ញុំក៏មានការទទួលការងារជាអ្នកបង្កើតការធ្វើកំណែទំរង់ការប្ដូរបែបបទថ្មីជាដើម។ទោះបីជាមិនមានជំនាញខាងផ្នែកគេហទំព័រក៏មិនជាបញ្ហាដែរ។យើងនឹងទទួលគាំទ្រការថែទាំរយៈពេលយូរដែលពោរពេញទៅដោយចំនេះដឹងនឹងបទពិសោធន៍។

### NEW ការលើកកំពស់ដល់ពលករជំនាញជនជាតិបរទេស

ពលករជំនាញជនជាតិបរទេសដែលមានសមត្ថភាពអាចធ្វើការងារបានយ៉ាងពូកែនៅកន្លែងការងារកំពុងមានការទាមទារអោយមានការគាំទ្រដល់ពួកគាត់។ខាងសមាគមន៍យើងខ្ញុំក៏បានចុះឈ្មោះក្នុងការគាំពារនឹងទទួលយកពលករជំនាញ។ហើយយើងបានបង្កើតប្រព័ន្ធសំរាប់ស្វែងរកក្រុមហ៊ុនដែលសាកសមនឹងត្រូវជាមួយសមត្ថភាពរបស់ពលករជំនាញជនបរទេសផងដែរ។

### NEW ការបង្កើតនឹងទិញរបស់របរប្រើប្រាស់ក្នុងការិយាល័យ

របស់របរដែលចាំបាច់ក្នុងការិយាល័យសមាគមន៍នឹងទិញសរុបដោយការទិញបែបនេះគឺវាមានតំលៃថោកជាងការទិញដោយម្នាក់ៗផងដែរ។

### NEW ការបន្ថែមការងារធានារ៉ាប់រងគ្រោះថ្នាក់ការងារ

ក្នុងករណីបញ្ជូនទៅកាន់មន្ទីរពេទ្យដោយសារគ្រោះថ្នាក់កំឡុងពេលធ្វើការងារប្រាក់ថ្លៃធានារ៉ាប់រង់គ្រោះថ្នាក់ការងារដែលបានពីខាងរដ្ឋប្រទេសជប៉ុនគឺមិនគ្រប់គ្រាន់នុះទេ។ដូច្នេះហើយយើងអាចបន្ថែមថ្លៃធានារ៉ាប់រងដើម្បីបំពេញប្រាក់ដែលខ្វះខាតផងដែរ។ប្រាក់ធានារ៉ាប់រងដែលចូលក្នុងសមាគមន៍គឺប្រើប្រាស់សំរាប់បញ្ចុះតំលៃក្នុងការព្យាបាល។

### NEW ការផ្គូរផ្គងក្នុងការជ្រើសរើសគូស្រករ

ផ្ដត់ផ្គងដល់បុគ្គលិកក្រុមហ៊ុនដែលមិនទាន់មានដៃគូរ「រៀបការ」។យើងបង្កើតនូវការផ្គូរផ្គងជ្រើសរើសគូស្រករនេះឡើងដើម្បីផ្ដល់ការរស់នៅរបស់បុគ្គលិកក្រុមហ៊ុនដែលចង់បង្កើតគ្រួសារនឹងបានធ្វើការដោយស្ងប់ចិត្តជាភាពងាយស្រួលដល់ក្រុមហ៊ុន។សមាគមន៍យើងខ្ញុំតែងតែគិតគូរដល់ការបង្កើតនូវសុភមង្គលដល់អ្នកទាំងអស់គ្នា។

## ការណែនាំបុគ្គលិករបស់សហជីព




**លេខាធិការដ្ឋានទំនាក់ទំនងសាធារណៈ:**
**លោកអុដាខែនជិ**(ODA Kenji)

**ការគ្រប់គ្រង:** ខ្ញុំជាអ្នកទទួលបន្ទុកកែសម្រួលអត្ថបទទំព័រដើម「អាជិគឺរិសឹស៊ីន」និងបន្ថែមទៀតនោះទទួលបន្ទុកគ្រប់គ្រងវគ្គសិក្សាភាសាជប៉ុន។ហើយធ្វើការពង្រឹងទំនាក់ទំនងរវាងក្រុមហ៊ុនសិក្ខាកាមនិងសហជីពផងដែរ!

**ភាពផ្ទាល់ខ្លួន:**ខ្ញុំចូលចិត្តទៅកន្លែងត្រាំទឹកក្ដៅនៅជុំវិញប្រទេសជប៉ុននិងជិះកង់ដើរលេង។រូបថតនេះគឺកន្លែងត្រាំទឹកក្ដៅនៅក្នុងស្រុកឈិបាក់។វាមានភាពល្បីល្បាញដោយសារតែគំនូរដើមស្រល់ដែលត្រូវបានគូរនៅលើជញ្ជាំងនៃកន្លែងត្រាំទឹកក្ដៅ។



**លេខាធិការដ្ឋានទំនាក់ទំនងសាធារណៈ:**
**លោកអារ៉ាកាវ៉ាហ៊ីរ៉ូយូគិ**(ARAKAWA Hiroyuki)

**ការគ្រប់គ្រង:**ខ្ញុំទទួលបន្ទុកបង្កើតគេហទំព័រ(Website) និងតំឡើងគេហទំព័ររបស់សហជីព។បន្ថែមទៀតនោះទទួលបន្ទុកពិនិត្យឯកសារក្រុមហ៊ុន។

**ភាពផ្ទាល់ខ្លួន** :ខ្ញុំស្ដាប់ចំរៀងជារៀងរាល់ថ្ងៃ។ខ្ញុំមានស៊ីឌី(CD)ជាច្រើនច្រើនខ្លាំងរហូតដល់សេវាចែកចាយតន្ត្រីមិនត្រូវការ។ហើយខ្ញុំកំពុងតែសន្សំលុយដើម្បីទិញឧបករណ៍លេងតន្ត្រីសម័យដើមដ៏ល្អមួយ។

## ចាប់ពីថ្ងៃទី1 ខែមីនាតទៅ
### ការចូលថ្មីមកកាន់ប្រទេសជប៉ុនកាន់តែងាយស្រួលសំរាប់ជនបរទេស

រដ្ឋាភិបាលជប៉ុនបានប្រកាសពីគោលការណ៍ថ្មីទាក់ទងនឹងការចូលថ្មីរបស់ជនបរទេស។ដោយផ្អែកលើគោលការណ៍នេះផងដែរការរឹតបន្តឹងលើការចូលថ្មីសម្រាប់ជនបរទេសត្រូវបានបន្ធូរបន្ថយបន្តិចម្ដងៗចាប់ពីថ្ងៃទី1 ខែមីនា។

### ករណីសម្រាប់សិក្ខាកាមនឹងពលករជំនាញជាជនបរទេស

តាមច្បាប់ទូទៅក្រុមហ៊ុនដែលទទួលយកបុគ្គលិកនឹងត្រូវបានអនុញ្ញាតការចូលថ្មីរបស់ជនបរទេសបានប្រសិនបើធ្វើការបំពេញពាក្យស្នើសុំតាមអ៊ីនធឺណិតរបស់ប្រព័ន្ធបញ្ជាក់សុខភាពនៃជនអន្តោប្រវេសន៍(ERFS)។

ដើម្បីទទួលបានទិដ្ឋាការ( Visa )បានអ្នកត្រូវការមានបង្កាន់ដៃដែលបានចេញបញ្ជាក់ដោយERFSក្រោយពីបំពេញរួច។

### រយៈពេលរងចាំនិងកន្លែងរង់ចាំ

លើសពីគោលការណ៍នៃការរងចាំរយៈពេល7ថ្ងៃបន្ទាប់ពីចូលប្រទេសជប៉ុនក៏មានដូចជា

- តើចូលមកពី「ប្រទេសដែលកំណត់រងចាំ3ថ្ងៃ」ដែររឺទេ?
- តើអ្នកមានក្រដាសបញ្ជាក់វ៉ាក់សាំងកូវីដត្រឹមត្រូវតាមតម្រូវការដែរឬទេ?

យោងតាមលក្ខខណ្ឌទាំងនេះរយៈពេលរង់ចាំនិងកន្លែងរង់ចាំមានការផ្លាស់ប្ដូរទៅតាមហ្នឹងដែរ។

【 FRESC 】ការប្រឹក្សាទូទៅពាក់ព័ន្ធអំពីការចូលប្រទេសដូចជាការស្នើរសុំទិដ្ឋាការ(Visa)ជាដើម

ការប្រឹក្សាជាភាសាកំណើតរបស់អ្នកទៅកាន់【**អង្គការហ្វឹកហ្វឺនជំនាញសម្រាប់ជនបរទេស**】

## ចាប់ពីថ្ងៃទី1 ខែមេសា
### ក្រុមហ៊ុនសំណង់នឹងផ្លាស់ប្ដូរចំនួនសិក្ខាកាមដែលអាចទទួលយក

ចាប់ពីថ្ងៃទី1 ខែមេសាតទៅចំនួនសរុបនៃសិក្ខាកាមដែលធ្វើការនៅក្រុមហ៊ុនផ្នែកសំណង់គឺមិនអាចលើសចំនួនបុគ្គលិកពេញម៉ោងបានទេ។

ករណីក្រុមហ៊ុនដែលជាប់ស្តង់ដារល្អ

សហជីពយើងខ្ញុំគឺជាអង្គការដែលមានការត្រួតពិនិត្យដ៏ម៉ត់ចត់។ប្រសិនបើក្រុមហ៊ុនដែលសិក្ខាកាមកំពុងធ្វើការជាក្រុមហ៊ុនដែលជាប់ស្តង់ដារល្អ(ក្រុមហ៊ុនដែលទទួលយកសិក្ខាកាមល្អៗដោយអង្គការដែលមានការត្រួតពិនិត្យដ៏ល្អ) ចំនួនមនុស្សមានដូចខាងក្រោម។

ចំនួនអតិបរមាគឺផ្អែកទៅលើចំនួនបុគ្គលិកពេញម៉ោង(ចំនួនបុគ្គលិកពេញម៉ោងមិនរួមបញ្ចូលសិក្ខាកាមទេ)។

## ដំណើរការនៃបើកប្រជុំសមាគមន៍អាស៊ីក្រិតសិន

សមាគមន៍អាស៊ីក្រិតសិនបានបើកការប្រជុំលើកទី11 កាលពីថ្ងៃ29 ខែកញ្ញាឆ្នាំ2021។ការប្រជុំនេះជាទូទៅធ្វើឡើងក្នុង1ឆ្នាំម្ដងដែលបុគ្គលិកនឹងសមាជិកទាំងអស់ត្រូវជួបជុំគ្នាដើម្បីសំរេចនៅមាតិការសំខាន់ៗ។លើកនេះពួកយើងបានពិភាក្សាទៅលើសំណើរចំនួន8 ដូចជារបាយការណ៍ការងារនិងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ2020 ហើយនិងផែនការអាជីវកម្មប្រចាំឆ្នាំ2021ផងដែរ។ហើយយើងទទួលបានការអនុម័តពីរបាយការណ៍ដែលសហជីពបានលើកឡើង។

【ចំពោះអ្នកកើតផ្កាសាយដោយលម្អងផ្កា】 មុនពេលជូតឬញីភ្នែករបស់អ្នក សូមលាងសម្អាតដៃរបស់អ្នកឲ្យបានស្អាតជាមុនសិន។សូមប្រុងប្រយ័ត្នមេរោគកូវីដទាំងអស់គ្នា។